# ការសម្ភាសរបស់ អ៊ុច ចន្ថា

កៈអ្នកសម្ភាសឈ្មោះ កុយសុភី ខៈអ្នកត្រូវគេសម្ភាសឈ្មោះអ៊ុច ចន្ថា

## <u>ពត៌មានសង្ខេបរបស់អ៊ុច ចន្ថា</u>

អ៊ុន ចន្ថា កើតនៅខែ៨ ឆ្នាំ១៩៦៤។ មានស្រុកកំណើតនៅក្នុងភូមិព្រៃទទឹង ឃុំជ្រៃវៀន ស្រុកព្រៃឈរ ខេត្តកំពង់ចាម។ មានបងប្អូនបង្កើតចំនួន៦នាក់ហើយបានចូលរៀនបានត្រឹមថ្នាក់ទី៨ និងបានរៀបការនៅអាយុ២៣ឆ្នាំមានកូន៣នាក់។ ចៃ អ៊ុចចន្ថា មានមុខរបបជាអ្នករកស៊ី កាលពីពេលមុនបានចាប់ដៃរកស៊ីជាមួយស្វាមីជាអ្នកលក់ ត្រី ចិញ្ចឹមត្រី ចិញ្ចឹមជ្រូក ទា ដើម្បីចិញ្ចឹមជីវិតនិងជីវៈភាពគ្រួសារតែមុខរបរនេះមិនបានជោគជ័យទាំងអស់នោះទេ មានខ្លះបានជោគជ័យហើយខ្លះបរាជ័យតែការខំប្រឹងតស៊ូនិងជំនះរាល់ការមើលងាយនិងសេចក្ដីលំបាក ធ្វើអោយចៃបានអោយកូនរៀនសូត្រគ្រប់គ្នា ។

កៈ ចាស! ខ្ញុំសូមជម្រាបសួរចៃ!

ខៈ ចាស! ជម្រាបសួរ!

កៈ តើសព្វថ្ងៃចៃសុខសប្បាយនោះទេចៅនេស?

ខៈ សុខសប្បាយ!

កៈ អូ!ចឹងខ្ញុំឈ្មោះកុយសុភីបានមកធ្វើការសម្ភាស នៅឆ្នាំចរសំរិតស័ក២៥៦២។ ចាសត្រូវនឹងខែកត្តិក ១២រោជ ថ្ងៃអង្គារ ទី៤ ខែធ្នូ ឆ្នាំ២០១៨។ចាសនាមត្រកូលនិងនាមឈ្មោះរបស់ចៃតើឈ្មោះអ្វី?

ខៈ អ៊ុច ចន្ថា!

កៈ ចឹងឈ្មោះហ្នឹងតើអ្នកណាជាអ្នកដាក់ឈ្មោះអោយ?

ខៈឪពុកម្ដាយហ្នឹង!

កៈ ចាសតើឈ្មោះ អ៊ុចចន្ថានុងតើមានអត្ថន័យយ៉ាងដូចម្ដេច?

ខៈ ចឹង!

កៈ
អត្ថន័យណាតើមានអត្ថន័យយ៉ាងម៉េចដែរ?ឪពុកម្ដាយអត់ដែរនិយាយជំណាល់ប្រាប់អីនោះទេហ៎?

ខៈ អត់

កៈ ចាសចឹងអឺ! តើចៃមានឈ្មោះហៅក្រៅ១ទៀតដេស?

ខៈ អត់ទេ!

កៈ តើចៃមានសញ្ជាតិជាអ្វី?

ខៈ ខ្មែរ!

កៈ សញ្ជាតិខ្មែរ ថ្ងៃ ខែ ឆ្នាំកំណើតកើតនៅ?

ខៈ ថ្ងៃទី៣

កៈ ខែ?

ខៈខែ៨

កៈ ឆ្នាំ?

ខៈ ឆ្នាំ១៩៦៤

កៈ ចាសហើយទីកន្លែងកំណើតកើតនៅក្នុងភូមិ?

ខៈ កើតនៅព្រៃទទឹងហ្នឹង!

កៈ ហើយទៅនៅភូមិព្រៃទទឹង ឃុំជ្រៃវៀនហោស?

ខៈ ហ្នឹងហើយឃុំជ្រៃវៀន!

កៈ ចាសចឹងនៅក្នុងឃុំជ្រៃវៀន ស្រុកព្រៃឈរ ខេត្ត?

ខៈ កំពង់ចាម

កៈ ចាសហើយចឹងតើនាមត្រកូនរបស់ឪពុករបស់ថៃគាត់ឈ្មោះអ្វី?

ខៈ អ៊ុច ជិន!

កៈ ចាសតើសព្វថ្ងៃនេះគាត់នៅរស់ហោស?

ខៈ ស្លាប់!

កៈ ចឹងគាត់ស្លាប់ហើយ!

ខៈ មិនមែនស្លាប់នោះទេ បែកគ្នាកាលជំនាន់៧៥នុង

កៈ កាលបែកគ្នានុងតើបែកយ៉ាងម៉េចដែរ ចូលថៃបកស្រាយមើល
ថាគាត់ធ្វើដំណើរទៅណាមកពីណា?

ខៈ នៅកាលនុងគឺថាគាត់បានមកកំពង់ចាម ហើយដល់ពេលដាច់នៅឆ្នាំ៧៥

កៈ ចាស

ខៈ ហើយដល់ពេល៧៥នុងដាច់ បានជាគាត់បែកតាំងពីពេលនុងមករហូត។

កៈ អូចឹងបែកបានធ្វើដំណើរមកបែករហូត?

ខៈ ចឹងមកធ្វើដំណើរមកជួបជុំគ្រួសារ។

កៈតើ ហើយរួចយ៉ាងម៉េចបានជាគាត់បែក?

ខៈ គាត់ធ្វើការ!

កៈ គាត់ធ្វើមន្ត្រីរាជការហោស?

ខៈ ហ្នឹងហើយ!

កៈ ក៏ប៉ុន្តែនៅផ្នែកអីដែរនៅពេលកាលនុង?

ខៈ គាត់ធ្វើប៉ូលីស

កៈ អូចឹងកាលនុងប៉ូលីសគេចល័តចឹង!

ខៈ អឺម

កៈ ចឹងអត់មានបានលឺដំណឹងដល់ឥឡូវហោស?

ខៈ ចាស! ហើយបានយកបងស្រី២នាក់ទៅតាមដែរ

កៈ ហើយចឹងបងស្រីនុងអត់ដឹងដែរ?

ខៈ អត់ដឹងទាំងអស់

កៈ គាត់បាត់ខ្លួនឯងហ៎?

ខៈ បាត់ដំណឹងទាំងអស់!

កៈ ចឹង៣នាក់?

ខៈ ៣ ទៅ៤នាក់នោះ ! នៅហ្នឹងតែ២នាក់នោះទេ
គេយកទៅវៃចោលនៅកាលជំនាន់ប៉ុលពតប្រុសៗ។

កៈ ចឹងអត់ដឹងនោះទេ
គាត់បាត់ខ្លួនចឹងមានបានដឹងថាគាត់បានរៀនដល់ត្រឹមថ្នាក់ទីប៉ុន្មានដែរបានជាគាត់ឈប់?

ខៈ ពីណា?

កៈ ឪពុកនុងណា!

ខៈ ឪពុកមិនដឹងថាគាត់រៀនបានត្រឹមថ្នាក់ទីប៉ុន្មាននោះទេ
ដឹងថាគាត់រៀនបានត្រឹមថ្នាក់ចប់ណា!

កៈ ចុះចឹងគាត់ចេះភាសាបរទេសដេស?

ខ៖ ចេះបារាំង! បានចេះភាសាបារាំង ហើយគាត់បានរៀនដូចជាពេទ្យចឹងណា។

ក៖ ចាសចឹងគាត់បានចេះដូចជាវិជ្ជាជីវៈអីបន្ថែមទៀត គឺពេទ្យនេស?

ខ៖ ពេទ្យ

ក៖ ចុះគាត់មានអត្តចរិតយ៉ាងម៉េចដែរ?

ខ៖ អត្តចរិតរបស់គាត់គឺគួរអោយគោរព ហើយបើសិនជាខ្ញុំនេះណា
កូនក៏គាត់អោយរៀនទាំងអស់ អត់ថាអត់មានអ្នកថាមិនរៀននោះទេ
។គាត់ចូលចិត្តអោយកូនរៀនណាស់! តែគ្រាន់តែថាគាត់អត់មានអីចែកអោយកូន
គាត់ចង់អោយកូនរៀនចេះដឹង។

ក៖ ចឹងបានចំណេះដឹងនុងហើយចែកអោយកូន!

ខ៖ ហ្នឹងហើយ! បានចំណេះដឹងមុខរបរនុងណា!

ក៖ចឹងមុខរបរ សំរាប់អោយមានចំណេះដឹងខ្ពស់ខ្ពង់ចឹងណា!

ខ៖ ហ្នឹងហើយ! គាត់មិនបានទៅជីកស៊ីអាឡេអាឡូអីដូចជាគេដូចឯងនោះទេ។

ក៖ចឹងមុខរបររបស់គាត់គឺធ្វើប៉ូលីលនិងពេទ្យ?

ខ៖ ហ្នឹងហើយ!

ក៖ ហើយទៅគាត់កើតតើគាត់កើតនៅក្នុងភូមិអ្វី?

ខ៖ គាត់កើតនៅភូមិត្រពាំងក្រោយ!

ក៖ ឃុំ

ខ៖ គេហៅថាខ្វាយៗចឹងទៅ

ក៖ ឃុំខ្វាយ

ខ៖ភូមិមៀន ដូចជាភូមិមៀន។

កះចឹងស្រុកព្រៃឈរដែរហោស?

ខះ ហោសស្រុក!

កះ ចឹងព្រៃឈរយើងដែរនុង

ខះ នៅត្រើងនុង នៅកន្លែងម្តុំត្រើងនុង ដឹងថាគេហៅថាភូមិអីគេ។

កះ អត់ស្គាល់ដែរ អត់ដឹងដែរ!

ខះ ហើយទៅ តើគាត់មានបងប្អូនចំនួនប៉ុន្មាននាក់?

កះ នៅចាំបានដែស?

ខះ ចាំមើលបងគេទី១ឈ្មោះអ៊ុច ភិន! ភេទប្រុស

កះ ចាចុះបងគេទី២?

ខះ បងទី២អ៊ុច ជិនហ្នឹងហើយ

កះ ចឹងហាំ!

ខះ អូបើសិនជាបងគេទី១ ឈ្មោះញឹម

កះ ហើយចុះទី២?

ខះ ទី២អ៊ុច ភិន ហើយទី៣ អ៊ុចជិន ប៉ារបស់ខ្ញុំហ្នឹង។

កះ ចាសទី៤?

ខះ ទី៤អ៊ុច ណាំ

កះ ទី៥?

ខះ អ៊ុច ឆាំង

កះ ទី៦?

ខ៖ ទី៦ អ៊ុចណម

ក៖ ចាអ៊ុច ណម

ខ៖ ទី៧ អ៊ុច ផេន!

ក៖ ចាសទៅចំណែកខាងម្ដាយថៃវិញនាមត្រកូលនិងនាមឈ្មោះ?

ខ៖ ដោម គីមណាង

ក៖ ចាស!ហើយចឹងមកដល់ពេលឥលូវនេះគាត់នៅរស់នោះទេណ៎?

ខ៖ចាសនៅរស់!

ក៖ ចុះគាត់មានអាយុ?

ខ៖ ៨១ឆ្នាំ!

ក៖ ៨១ហើយ! ចឹងនៅកាលនុងគាត់ មានអត្តចរិតយ៉ាងម៉េចដែរ?

ខ៖ អត្តចរិតរបស់គាត់ គឺគាត់ស្លូតបូតនៅស្រុកភូមិនុង
គាត់មិនដែរនេះជាមួយនឹងអ្នកណានោះទេ!

ក៖ គាត់សញ្ជាតិអ្វី?

ខ៖ សញ្ជាតិខ្មែរ!

ក៖ ចុះគាត់កាន់សាសនាអ្វី?

ខ៖ កាន់សាសនាព្រះពុទ្ធ!

ក៖ អើ! សញ្ជាតិរបស់គាត់ខ្មែរ ហើយកាន់សាសនាព្រះពុទ្ធ
ហើយចុះដឹងថាឆ្នាំរបស់គាត់តើមានឈ្មោះអ្វី?

ខ៖ ឆ្នាំថោះ!

ក៖ ឥឡូវគាត់អាយុ?

ខ៖ ៨១

ក៖ ៨១! ទីកន្លែងកំណើតរបស់គាត់កើតនៅក្នុង?

ខ៖ ភូមិពាមក្នុង!

ក៖ ចាសនៅពាមក្នុងហ្នឹង តើបងប្អូនរបស់គាត់ប៉ុន្មាននាក់ដែរ?

ខ៖ បងប្អូន! ...បងប្អូនរបស់គាត់៥នាក់!

ក៖ ចាសចឹងបងទី១ឈ្មោះ?

ខ៖ គាត់នុង

ក៖ ហើយមកទី២?

ខ៖ ទី២មេគង់!

ក៖ ចាស!ទី៣?

ខ៖ ទី៣នីន

ក៖ ទី៤?

ខ៖ ទី៤ ថានី ទី៥ ម៉ុល!

ក៖ ចាសដាក់ត្រកូលជាមួយនឹងម្តាយ?

ខ៖ ចាស

ក៖ ហើយបានមកអើ! បងប្អូនថៃតែម្តង តើមានបងប្អូនប៉ុន្មាននាក់?

ខ៖ បងប្អូន៦នាក់

ក៖ ចុះបងទី១?

ខ៖ បងទី១ អើចុះអ្នកស្លាប់រាប់ដែរ?

កៈ រាប់!

ខៈ រាប់ហោស?

កៈ ចាស

ខៈ បងទី១ អ៊ុចទឹមឃីម!

កៈ ស្រីហោស?

ខៈ ប្រុស!

កៈ ប្រុសទេ! ហើយទី២?

ខៈ អ៊ុចគឹមយ៉ន

កៈ ស្រីឬក៏ប្រុស?

ខៈ ប្រុស!

កៈ ទី៣?

ខៈ អ៊ុចគឹមឈីម! ស្រី

កៈ អូស្រី!

ខៈ អ៊ុចសំអនប្រុស!

កៈ ចា

ខៈ ហើយអ៊ុចសំណានក៏ប្រុសដែរ!  អ៊ុចគឹមណា ហើយបានមកខ្ញុំអ៊ុចចន្ថាហ្នឹង អ៊ុចចន្ថី អ៊ុចចាន់ដារ៉ា អ៊ុចចន្ធី អ៊ុចចាន់ដារ៉ាត។

កៈ ចាស! ហើយចឹងថៃបានរៀបអាពាហ៍ពិពាហ៍នៅឆ្នាំណា?

ខៈ នៅឆ្នាំ១៩៨៧ ជិតចូល៨៧ហើយ នៅថ្ងៃ៦មករាចឹងចូល៨៧ហើយ។

កះ ចាសចឹងចែការនៅអាយុប៉ុន្មាន?

ខះ អាយុ២៣ឆ្នាំ!

កះ ចែចូលរៀនហើយបញ្ចប់ត្រឹមថ្នាក់ទីប៉ុន្មាន?

ខះ កាលនុងរៀនចប់ បានរៀនត្រឹមថ្នាក់ទី៨!

កះ ចុះសាលាយើងរៀននុងតើមានឈ្មោះអ្វី?

ខះ សាលានៅកំពង់ចាមនេះមិនបានដឹងថាឈ្មោះអីនោះទេ។សាលាដូចជា ទាក់សិន!

កះចឹងនៅជិតវត្តដីដុះ! អូមិនមែននោះទេ នៅជិតពោងមហោស្រប!

ខះ ហ្នឹងហើយ!

កះ ចឹងនៅបឹងកុង?

ខះហ្នឹងហើយ

កះ ចឹងសាលាទាកសិនចឹងហេស?

ខះ ហ្នឹងហើយ

កះហើយចឹងចែចេះភាសាដែស?

ខះ អត់ចេះនោះទេ បារាំងចេះតែគោលៗបានបន្តិចនុង ហើយរៀននៅកាលនុង
វានៅស្ទើរដែរនុងណា។

កះចឹងចប់ពេលនុងទៅ ដល់ចឹងតើចែមានមុខរបរអ្វីដែរនៅកាលនុង?

ខះ អត់មានមុខរបរអ្វីនោះទេ នៅក្មេងដែរនុង! អាយុ១១

កះ ចឹងពេលនុងរៀនចប់ត្រឹមនុងហើយអត់មានបានការងារអ្វីធ្វើ?

ខះ ធ្វើអីកាលនុងរៀនហើយចប់យើងនៅក្មេងដែរ ហើយស្រុកកើតសង្គ្រាម។

កៈ ចឹងអត់បានការងារអ្វីធ្វើ
ហើយរៀនចប់ចឹងទៅថាគ្រែងលោបានធ្វើគ្រូបានជាគេសួររកមុខរបរនុងណា!

ខៈ ហ្នឹងហើយ! នៅកាលនុងគេហៅធ្វើគ្រូដែរ!
គ្រូបង្រៀននៅហ្នឹងកាលដំបូងជំនាន់គ្រូអ្វូនោះ។

កៈ ចាស

ខៈ ចឹងគ្រូស្រីលនុងហៅអោយធ្វើគ្រូបង្រៀនតែអត់បានធ្វើនោះ។

កៈ ចាស!

ខៈ ចឹងគ្មានបានធ្វើអី គាត់អោយទៅរៀនថ្នាក់មតេយ្យ។

កៈ ចាស

ខៈ រៀនគ្រូមតេយ្យរៀនចប់ហើយតែសាលានៅហ្នឹងអត់បើក!

កៈ អត់បើកទេ!

ខៈ ហ្នឹងហើយ បើសិនជាភូមិគេនោះគេបានបើក ចឹងអត់រហូតតាំងពីនុងមក
រៀនបានត្រឹមគ្រូមតេយ្យនុងណា!

កៈ ចឹងដល់ពេលនាមត្រកូលនិងនាមខ្លួនរបស់ប្តីចៃតើឈ្មោះអ្វី?

ខៈ ឈ្មោះ អ៊ិនវ៉ាណា!

កៈ ចុះថ្ងៃខែឆ្នាំកំណើតរបស់គាត់កើតនៅ?

ខៈ កើតនៅ១៩៦១!

កៈ ចុះខែអត់ចាំនោះទេ?

ខៈ អត់បានចាំនោះទេ គាត់ឆ្នាំឆ្លូវ!

កៈ ចឹងគាត់បានចូលសិក្សាបានត្រឹមថ្នាក់ទីប៉ុន្មានដែរ?

ខ៖ គាត់បានត្រឹមថ្នាក់ទី៨ដែរ!

ក៖ នៅពាមជីកងនេះ?

ខ៖ នៅពាមជីកង!អាថ្នាក់ទី៨ចាស់ណា!

ក៖ ចា

ខ៖ ចឹងនៅកាលនុងគេរាប់ពីថ្នាក់ទី៨មក!

ក៖ ចឹងពេលនុងរាប់ចាប់ពីបាក់ឌុប?

ខ៖ អឺម

ក៖ ចឹងស្មើនឹងថ្នាក់បាក់ឌុបហើយថ្នាក់ទី៨នៅកាលនុង!

ខ៖ អឺម!ចូលទី៩ ចូលរៀនបារាំងហើយនៅកាលនុងខ្ញុំធ្លាប់រៀន ។

គ៖ ចឹងមុខរបររបស់គាត់! គាត់មានបានរៀនចប់ហើយចេញទៅធ្វើអីនោះផង?

ខ៖ អត់នោះទេ

ក៖ ចឹងអត្តចរិតរបស់គាត់យ៉ាងម៉េចដែរ?

ខ៖ អត្តចរិតរបស់គាត់ស្លូតបូត មើលតែនៅពេលឥឡូវនេះដឹងហើយ!

ក៖ ចាហើយចុះទីកន្លែងកំណើតរបស់គាត់នៅក្នុងភូមិ?

ខ៖ នៅក្នុងភូមិដំណាក់ស្នាយ! ឃុំពាមជីកង ស្រុកកងមាស ខេត្តកំពង់ចាម។

ក៖ចាស!ចុះមូលហេតុអ្វីបានជាគាត់នៅខាងនេះ គាត់នៅពាមជីកង
ហើយចឹងថៃនៅពាមក្នុងនេះបានមកដណ្តឹងថៃដល់ហ្នឹង ដោយសារអ្វី?

ខ ដោយសារគាត់បានមកនៅហ្នឹង គាត់បានមកធ្វើការនៅរោងម៉ាស៊ីនជាមួយនឹងអីនេះ។

ក៖ អូហើយចឹងក៏បានឃើញ!

ខ៖ឃើញចឹងទៅ គាត់ត្រូវចិត្តគាត់ដណ្ដឹង។

ក៖ ចាសចឹងបានប្រាប់ចាស់ទុំអោយចូលស្ដីដណ្ដឹងចឹងទៅណា?

ខ៖ ចាស!

ក៖ អូ! ដល់ពេលអើ! រៀបអាពាហ៍ពិពាហ៍ហើយៗ
យើងចាប់ដៃគ្នាកសាងជាគ្រួសារមួយហើយតើចែប្រកបមុខរបរអ្វី២នាក់ប្ដីនិងប្រពន្ធនុង?

ខ៖ កាលនុងធ្វើចំការ!

ក៖ ធ្វើចំការ

ខ៖ ធ្វើចំការធ្វើស្រែ! តែថានៅកាលនុងធ្វើអត់មានបាននោះទេ
ហើយក៏បានឈប់ប្ដូរ!មុខរបរនុងទៅ។

ក៖ ចាស!ធ្វើស្រែចំការនុងតើដូចថា ធ្វើៗទៅមានជួបការលំបាកយ៉ាងម៉េចដែរ
ការធ្វើស្រែចំការនុង?

ខ៖ ជួប ធ្វើស្រែនុងយើងអត់មានអីធ្វើនោះទេ ព្រោះយើងអត់មានអីជួលគេទាំងអស់
ហើយទៅស្រែនោះក៏ចឹងដែរ ជួបនឹងទឹកជំនន់ធ្វើអត់បាន!
ទឹកជំនន់នៅកាលនុងជន់លិចតែម្ដង ស្រូវចេញចឹងទៅហើយលិច។

ក៖ អូចឹងអត់មានបានមកវិញផង!

ខ៖ អត់មានបានមកវិញនោះទេ គ្មាននោះទេ!

ក៖ ចាស

ខ៖ ផ្កាអីក៏ចឹងដែរ អត់មានប្រើថ្នាំអីដូចជានៅពេលឥឡូវនេះនោះទេ! កាលនុងណា
ហើយដង្កូវក៏វាស៊ីតាមដំណើរចឹងទៅណា។

ក៖ ហើយមានដែរបានជួបនឹងគ្រោះរាំងស្ងួតអីដែស?

ខ៖ហ្នឹងហើយរាំង!

កៈ ចឹងមានជួបដែរ?

ខៈ មានជួប ! ជួបរាំងស្ងួតហ្នឹងហើយដែរវាអត់មានទឹកអត់មានអី អន្ទៀមអីក៏អត់មាន វាមានតែខ្យល់ណា!

កៈ ចឹងមានតែដង្កូវស៊ី?

ខៈ មានដង្កូវស៊ីឡើងរិច!ដល់គុល ហើយអត់មានអ្នកណាបាននោះទេនៅពេលឆ្នាំនុងហ៎។

កៈ ចាស!

ខៈ ចាស

កៈ ហើយចឹងមកចៃ?

ខៈ ក៏បានផ្លាស់ប្តូរលក់ពីដីចំការនុងទៅ! តែលក់ដីចំការនុងវាមិនបានធំអីដែរ វាតូច តែ៣ម៉ែត្រកន្លះនុង បណ្តោយវែងមែនប៉ុន្តែវាតូចដូចថាយើង មើលទៅវា

កៈ ដូចថាធ្វើអាហ្នឹងវាមិនគ្រាប់គ្រាន់!

ខៈ ចាស

កៈចឹងក៏សំរេចចិត្តផ្លាស់ប្តូរមុខរបរ?

ខៈ ហ្នឹងហើយ

កៈ ដល់ពេលផ្លាស់ប្តូរមុខរបរនុងចៃធ្វើអីទៀត?

ខៈ ធ្វើអីទិញត្រីអីលក់ចឹងទៅ!

កៈ ចាស

ខៈ ចា

កៈ ចឹងធ្វើងីគេទៀត?

ខៈ ចិញ្ចឹមទាអីទៀតចឹងទៅ

កៈ ចាសដល់ពេលការបានប៉ុន្មានឆ្នាំបានថៃមានកូនបងគេទី១?

ខៈ ការបាន២ឆ្នាំ!

កៈ ចឹងចោលពោះបាន២ឆ្នាំដែរបានមានកូន!

ខៈ ចាសបានកូនបង!

កៈ ចឹងតាំងពីការនុងមកតើថៃមានតែជួបអំពើហិង្សានៅក្នុងគ្រួសារដេស?

ខៈ អត់មានដែរជួបនោះទេ

កៈ ហើយចឹងដូចថាមានទ្រាំដែលមានធ្វើបាបចិត្តថៃអី?

ខៈ រឿងចិត្តនោះអត់មាននោះទេ តែថាភាពក្រលំបាកវាដូចថាយើងអត់ទាំងអស់គ្នាណា។

កៈ ចាស!

ខៈ ប៉ុន្តែបើសិនជាថាអោយគាត់មកធ្វើបាបចិត្តដល់យើងនោះគឺអត់មានទេ។

កៈ ចាស!

ខៈ គាត់មិនដែលបានធ្វើបាបចិត្តនោះទេ និយាយរួចដូចថាសំណាងរបស់យើងដែរ គាត់មិនដែរមកធ្វើបាបយើងនោះទេ! ទោះបីមានក្រ អត់ស៊ីយ៉ាងម៉េចក៏គាត់មិនដែររអ៊ូរទាំធ្វើបាបអីយើងដែរ។ និយាយថាពេលកូនខ្ចីនិមួយៗ និយាយពីថាគាត់ថ្នាក់គាត់ថ្នមយើងល្អជាអ្នកមានទៅទៀតប្រាប់ទៅ។

កៈដឹងធុរៈយើងដែរ

ខៈ ហ្នឹងហើយដឹង សូម្បីតែបាយដូសដាក់នៅចុងជើងយើងនេះ ហើយដល់ពេលព្រឹកព្រលឹមយើងដឹងថាទិញអីធ្វើទុកអោយយើងរួចជាស្រាច់ គាត់ទៅធ្វើការអីគាត់ហើយបានរួចបានគាត់ទៅធ្វើការ នៅខាងក្រៅទៅ។

កៈ ចាសដូចថាបានបំពេញភារៈកិច្ចជាមេគ្រួសារ!

ខៈ ហ្នឹងហើយ!ជាមេគ្រួសារ

កៈ ចឹងជាស្វាមី១ដូចថាបំពេញភារៈកិច្ចគាត់នុងមិនអោយយើងទើសចិត្តណា!

ខៈ ហ្នឹងហើយ

កៈ ចឹងតាំងពីនុងមក តាំងពីកូនមួយៗមក!

ខៈ តាំងពីកូនដំបូងរហូតបានដល់កូនទាំង៣គាត់នុង!

កៈ ចឹងមិនដែរបានអោយចៃលំបាកចិត្តនោះទេ!

ខៈមិនដែរថាអោយលំបាកចិត្ត ខឹងរឿងអីទៅណាទៅនៃយំស្រែអីនោះទេ! មានតែធ្វើអោយយើងស្រួលចិត្តមិនលំបាក មានតែប្រាប់យើងផឹកនេះផឹកនោះ!

កៈ ចឹងអត់អោយយើងតូចចិត្តនោះទេ?

ខៈ អត់ទេ!

កៈ ចឹង

ខៈ មិនដែរសោះនិយាយមែនណា! និយាយត្រង់តែម្តង ចេញពីនៅក្នុងចិត្ត!

កៈ ចាស ហើយចឹងមកដល់ពេលឥឡូវនេះចៃមានកូន៣នាក់ណំ!

ខៈ កូន៣!

កៈ ចឹងកូនទី១ កូនច្បងគេនោះតើមានឈ្មោះអ្វី?

ខៈ អេនលីដា!

កៈ អេនលីដាភេទស្រីចឹងហោស?

ខៈ ភេទស្រី

កៈ ចាសហើយថ្ងៃខែឆ្នាំកំណើតរបស់គាត់?

ខៈកើតនៅថ្ងៃទី៨ ខែ៧ឆ្នាំ១៩៨៩!

កៈ អូចាសហើយចុះទីកន្លែងរបស់គាត់កើតនៅឯណា?

ខៈ នៅភូមិ !កាលកើតនុងនៅជំណាក់ស្នាយណា

កៈ ចាស!

ខៈ
នុងហើយកើតនៅនុងកាលនុងម្ដាយក្មេងរបស់ខ្ញុំឃើញខ្ញុំនៅតែឯងចឹងណាហើយគាត់បានប្រាប់ថាអោយខ្ញុំទៅកើតនៅឯនុងបានគាត់ជួយថែទាំម។

កៈ អូ បានកើតនៅនុងជំណាក់ស្នាយ ឃុំអ្វី?

ខៈ ឃុំពាមជីកង

កៈ ចុះកូននុងបានសិក្សាដល់កំរិតណា?

ខៈ កូនបានសិក្សាបានរៀនដល់ចប់៨ឆ្នាំទៀតនោះតើនុងគេបានហៅថាអ្វីគេ?

កៈ ចឹងកូននុងនិស្សិតបានទទួលបានបរិញ្ញាប័ត្រហើយ!

ខៈ ចាស!

កៈ ហើយទៅគាត់បានធ្វើការងារអ្វី?

ខៈ ឥលូវហ្នឹងធ្វើជានេះ កាលពេលមុនដំបូងគាត់បានធ្វើជាគ្រូបង្រៀនណា!

កៈ ចាស!

ខៈ
ហើយមកដល់ពេលឥឡូវនេះគេបានប្ដូរអោយគាត់បានមកធ្វើជាអ្នកគ្រប់គ្រងជានាយកវិញ!

កៈ ចឹង! តែមកដល់ពេលឥឡូវនេះគាត់មានគូស្រករនៅ?

ខៈ នៅ

កៈ កូនទី២ឈ្មោះអ្វី?

ខ៖ អេនលីដូ!

ក៖ចាសចុះគាត់ថ្ងៃខែឆ្នាំកំណើតរបស់គាត់?

ខ៖ កើតនៅឆ្នាំ១៩៩១

ក៖ ចុះទីកន្លែងកំណើតរបស់គាត់?

ខ៖ កើតនៅនេះដែរ! នៅជំណាក់ស្នាយដែរ

ក៖ ចាសហើយចឹងគាត់បានចូលសិក្សាដល់ថ្នាក់ទីប៉ុន្នានដែរ?

ខ៖ ទី៩!

ក៖ ទី៩! ហើយទៅគាត់បានបញ្ចប់ត្រឹមថ្នាក់?

ខ៖ កាលនុងគាត់កើតគ្រុនពោះរៀនហើយដល់ពេលចឹងបកទៅគេប្រលងបញ្ចប់រួចទៅ ចំពេលប្រឡងនុង ។ គ្រុនពោះវផននុងលាបកាលនុងវាបានទៅប្រឡងបាន១ថ្ងៃចឹងណា ហើយដល់ពេលបកមកវិញក្តៅឡើងលាបចឹងទៅ ហើយក៏អត់មានបានទៅរហូតអត់មានបានទៅឯណា!

ក៖ រួចទៅឥលូវនេះតើគាត់បានប្រកបមុខរបរអ្វីដែរ?

ខ៖ ឥឡូវមានអីដល់ពេលឥលូវនេះនៅតែផ្ទះនុង ជូនការគេហៅទៅដឹកត្រីអីចឹងទៅ។

ក៖ ហើយចឹងទៅចុះកូនទី៣គាត់ឈ្មោះអ្វី?

ខ៖ កូនទី៣ឈ្មោះ អេនស្រីលក្ខ័!

ក៖ ចាស! ចុះថ្ងៃខែឆ្នាំកំណើតរបស់គាត់?

ខ៖ ១៩៩៩!

ក៖ ចុះគាត់បានសិក្សាដល់ត្រឹមថ្នាក់ទីប៉ុន្នានដែរ?

ខ៖ ដល់ត្រឹមថ្នាក់ទី១២! ទៅរៀនបាន២ឆ្នាំ!

កៈ ចាស! ចឹង២ឆ្នាំផ្នែកខាងអី?

ខៈ ផ្នែកខាងគណនី!

កៈ គណនីចាស! ចុះរៀនហើយ២ឆ្នាំនុងចប់ហើយឬក៏នៅ?

ខៈ នៅ! ២ឆ្នាំទៀតបានយកបរិញ្ញា!នៅ២ឆ្នាំទៀត!

កៈ អូចឹងហ៎! ចុះមកមានកូនទីប៉ុន្មានទៀតឬក៏អស់ហើយ?

ខៈ អស់ហើយ! មានកូនតែត្រឹមហ្នឹង!

កៈ អូ! ហើយទៅចៃ! ចាសចឹង
នៅក្នុងមួយឆាកជីវិតរបស់ចៃហ្នឹងតើមានបទពិសោធន៍អ្វីដែលគួរអោយចង់ចាំនៅក្នុងជីវិតរបស់ចៃ! មានបទពិសោធន៍អ្វីដែរ?

ខៈ បទពិសោធន៍ដូចថាយើងគ្មានណា!

កៈ ចាស

ខៈ ដូចថាយើងរស់នៅជិតខាងយើងហើយក៏មានក្ដីស្រលាញ់ជាមួយនឹងអ្នកជិតខាងដែរ ថារកអីគេទៅខ្ចីនេះខ្ចីនោះអីចឹងទៅណា !

កៈ ចាស

ខៈ ចឹងជួនកាលគេនិយាយថា
ឧបមាថាប្ដីរបស់ខ្ញុំទៅខ្ចីទូករបស់គេយកមកដាក់ត្រីចឹងព្រោះអីយើងវាអត់ទាន់មានទូកមានអីចឹងណា វាអត់ទាន់មានសំភារៈគ្រាប់គ្រាន់ដល់ចឹងទៅយើងបានទៅខ្ចីគេចឹងទៅហើយ គេថាអោយទៅដែរ! ដល់ពេលហើយចឹងទៅគេអត់បានអោយទៅនោះទេ ហើយយើងនេះថាឈឺចាប់ណាស់ណា យើងដេកគិត២នាក់ប្ដីនិងប្រពន្ធថា វាមិនគួរនោះទេណា ដូចថាខ្មាសគាត់ឬក៏អី ដល់គិតៗទៅយើងក៏គិតថា ចឹងខំប្រឹងដាក់ជ្រូក១ចិញ្ចឹម លក់បានទិញទូក១បានប្រើហើយខ្ញុំក៏បានគិតថា អូ ខ្ញុំអរគុណហើយដែលបានធ្វើអោយខ្ញុំឈឺចាប់ណា

ខំប្រឹងរកលុយយកមកទិញរបស់រកស៊ីណា! យើងបានឈឺចាប់ទៅខឹងគេចឹងទៅ ចុងបញ្ចប់ខ្ញុំអរគុណគេវិញ ។ ពេលមុនដំបូង! ខ្ញុំបានទូចចិត្តណាស់ណា!

ក៖ ចាស

ខ៖ ជាចុងបញ្ចប់ខ្ញុំបានអរគុណគេដែលគេធ្វើអោយខ្ញុំរឹងម៉ាំងណា!

ក៖ ចាសចឹងថៃបានខំប្រឹងទិញបានឧបករណ៍ដូចជាទូកអីចឹងទៅ ហើយទីអីឧបករណ៍ទៀតទៅ!

ខ៖ ចាស!

ក៖ ចាសៗចឹងទៅបានមានយានជំនិះអីបន្តបន្ទាប់ចឹងទៅ!

ខ៖ ចាសបាន បន្តបន្ទាប់ចឹងទៅនូវអ្វីដែលយើងបានខំប្រឹងហ្នឹងណា!

ក៖ ចឹងការខំប្រឹងរបស់យើងនុង តើយើងមានបានជោគជ័យដេស?

ខ៖ ដូចថាវាបានជោគជ័យដែរ ក៏ប៉ុន្តែ ពេលខ្លះយើងបានដូចថាកំពង់បានជោគជ័យអីមួយចឹងទៅស្រាប់តែរកទៅប៉ះ បរាជ័យអីទៀតទៅ!

ក៖ ចឹងណា នៅក្នុងឆាកជីវិតរបស់ថៃ ដែលបានខំប្រឹងអោយបានជោគជ័យហ្នឹងបានចំនួនប៉ុន្មានដងហើយបានបរាជ័យប៉ុន្មានដង?

ខ៖ ជោគជ័យនុងដូចថាយើងប្រឹង កាលពីមុនយើងអត់មានអីសោះចឹងណា កាលពេលមុនដំបូងយើងបានកង់កញ្ចាស់១ បានមក២នាក់ប្តីប្រពន្ធចឹងណា ថាខែទឹកចឹងយើងរកត្រី នាំគ្នាធ្វើអីៗដាក់ចឹងទៅកាលពីមុនដំបូងគឺមានទឹករាកណា!

ក៖ ចាស

ខ៖ ដល់ពេលទឹកជ្រៅចឹងទៅ ក៏ទៅខ្ចីទូកគេ ដល់ពេលគេអត់មានអោយចឹងទៅក៏បាននាំគ្នាថាខំប្រឹងទៀតហើយ ប្រឹងដើម្បីអោយបានទូក ដល់ពេលបានទូកនុងហើយក៏ខំប្រឹងជោគជ័យម្តងហើយម្តងទៀតចឹងណា។

ក៖ ចាស

ខ៖ ដល់ពេលយើងរកទៅបានដើមទុករាងធំចឹងទៅណា ហើយក៏បានធ្វើរបាំងចឹងទៅ
តែដល់ពេលទឹកនោះវាមិនអំណោយផលចឹងទៅក៏វាបរាជ័យអានុងអស់ទៅ
វាអស់ទៅលើរបស់នុងវាអត់មានបានលក់អីបានវិញនោះទេណា។

ក៖ ចាស!

ខ៖ ចាស!បាន១សារទៀតចឹងទៅ
ហើយដល់ពេលមួយសារទៀតនោះគឺថា២នាក់ប្ដីនិងប្រពន្ធនុងនាំគ្នាដាក់ជ្រូក
ហើយដល់ពេលជ្រូកនុងវាចុះថ្លៃចឹងទៅ ក៏វាខាតទៀត ខាតនុងដូចថាវាបន្តបន្ទាប់ចឹងទៅណា
។

ក៖ ចាសចឹងវាផ្ទួនៗគ្នា!

ខ៖ ចឹងវាខាតនុងណា ថាងើបវាមិនចង់រួចណា ខាតនុង!

ក៖ ចាស

ខ៖ ចឹងហើយបាននាំគ្នាដាក់ទា! ទានុង បានកើត ងើបចឹងទៅ
បានចឹងទៅយើងនេះក៏បានរាងបានទិញម៉ូតូ
ដល់ពេលដាក់មួយសារទៀតក៏ងាប់ទាំងអស់តែម្ដងនុងខាតធំណាស់ណា! ខាត!។

ក៖ អូខាតទៅវិញទៀត!

ខ៖ នុងហើយ! ដល់ចឹងខ្ញុំប្រហែលជាកន្លះខែ
រាងថាស្រាកជំងឺនុងខ្ញុំក៏បានដើរទិញទាមកបន្ថែមទៀត
ហើយបានទៅខ្ចីលុយបងប្អូនខ្លះអីចឹងទៅណា។

ក៖ ចាស!

ខ៖ ហើយបានមានបងប្អូននៅភ្នំពេញអីចឹងខ្លះទៅណា!

ក៖ ចាស!

ខ៖ អូ

ក៖ ហើយដល់ពេលអានេះបានតែប៉ុណ្ណោះចឹងទៅណា!

ខ៖ ចាស

ក៖ហើយបានយកមកទិញបន្ថែមទៀតចឹងទៅ បានដាក់ចឹងទៅក៏បានងើបទៀតចឹងទៅ! បានមួយសារទៀតចឹងទៅ! ហើយការតស៊ូជាមួយនឹងកូននោះក៏ចឹងដែរ គ្មានលុយអោយកូនបានទៅរៀននោះទេ ចឹងកូននោះគេបានចេះតែសួរថាឥឡូវនេះខ្ញុំបានរៀនសូត្រ ថ្នាក់ទី១២បានជាប់ហើយតើចឹងម៉ាក់ឯង អោយខ្ញុំទៅរៀននៅឯភ្នំពេញដេស?

ខ៖ ទៅកូនម៉ែមានលុយ! ចុះកូននោះវាអត់មានដឹងថាយើងអត់ឬក៏មាននោះទេណា!

ក៖ ចាស

ខ៖ ចាសថាម៉ែមានលុយអោយកូនរៀន ចឹងទៅរកមើលសាលា ហើយចឹងបានរកដោយខ្លួនឯងអីទាំងអស់រៀននុង។

ក៖ ចាស

ខ៖ ចឹងខ្ញុំបានតស៊ូអោយកូនរៀនទាល់តែចប់ទៅ។

ក៖ ចាស

ខ៖ រកចឹងទៅ!

ក៖ ហើយថៃដូចថាតាំងពីដឹងក្តីមក តើថៃបានឆ្លងកាត់សង្គមណាខ្លះ?

ខ៖ តាំងពីបានដឹងក្តីមកឆ្លងកាត់សង្គមលន់ណល់! ខ្ញុំបានជួបប្រទះសង្គ្រាមនៅឆ្នាំ៧០!

ក៖ ចាចុះពីលន់ណល់មក!

ខ៖ បានលន់ណល់ទៀតនុង បានទាន់តែលន់ណល់នោះទេណា ព្រោះអីខ្ញុំដឹងក្តីនៅកាលជំនាន់លន់ណល់។

កៈ ចាស!ដល់ពេលរាងធំបន្តិចមកក៏នៅក្នុងរបបលន់ណល់ដែរ?

ខៈ ចាស! ក៏នៅក្នុងរបបលន់ណល់ដែរ!

កៈ ចាសចឹងនៅក្នុងរបបលន់ណល់នុងដូចថាមិនទាន់ចូលស៊ុបចឹង!

ខៈ នៅឆ្នាំ៧០នុងគឺជាឆ្នាំដែរគេបាតុកម្មទំលាក់សម្តេច! ជាលន់ណល់នុងណា

កៈ ចាស

ខៈ ដល់ចឹងលន់ណល់បានឡើងកាន់កាប់!

កៈ ចឹងខ្ញុំអត់ដឹងដែរ ចូលថៃនិយាយអំពីជីវៈប្រវត្តិនុងមើល?

ខៈ ចាស កាលនុងខ្ញុំនៅតូចដែរនោះទេកាលនុងនៅជំនាន់នុងនៅតូច។

កៈ ចុះមានបាតុកម្មអីនុងថៃដឹង?

ខៈ ដឹងតើ! ខ្ញុំទៅឈរមើលគេទៀតណ៎!

កៈ អូ!ចាស

ខៈ គេកាលនុងមិននេះអីនោះទេ គេនាំគ្នាឈរស្រែកធ្វើបាតុកម្មទំលាក់សម្តេច ស្រែ!

កៈ ចឹងចាស គេបានដើរយោស្នាស្រែកចឹងទៅក៏ធ្លាក់!

ខៈ ហែក! ដូចជានៅក្នុងឆ្នាំ៧០នុងដូចជាលន់ណល់បានទំលាក់ហើយទេដឹងនេះ!

កៈ ដឹងអីថៃ! ដឹងថាបានធ្លាក់ហើយបានចូលទៅដល់របបលន់ណល់នុង!

ខៈ លន់ណល់នុងដូចថានៅម៉ាក្រវិចតូចនោះទេ ព្រោះអីកាលនុងនៅជំនាន់លន់ណល គេហៅថាពួកខ្មែរក្រហមនុង ហៅយ៉ៃកកុងៗ។

កៈចាសយ៉ៃកកុងៗ!

ខៈ ដូចថានៅម៉ាខេត្តកំពង់ចាមចឹងខាងតារបស់ខ្ញុំអីនៅហ្នឹងបាន កាន់កាប់ទៅអស់ហើយ កាលនុង កាលនៅឆ្នាំ៧០នោះខ្ញុំនៅខាងកំពង់ចាមនុង

រួចទៅដល់ពេលនេះចឹងទៅបែកនៅឆ្នាំ៧៣នុងបានដាច់មួយសារចឹងទៅ
បានហើយមកដាច់នៅឆ្នាំ៧៥ហ្នឹង ចប់នៅឆ្នាំ៧៥ហ្នឹង។

ក៖ ហើយបានចូលមកដល់នៅប៉ុលពតនៅឆ្នាំ?

ខ៖ ៧៦ទៅ៧៧ទៅ៧៨

ក៖ ៧៩ដាច់!
ដល់មកចៃបានពេញវ័យហើយបានចូលមកដល់សម័យប្រល័យពូជសាសន៍ម្ដង។

ខ៖ ចាសនៅកាលនុង១៨ឆ្នាំ

ក៖ចានៅកាលនុង១៨ចឹងគេបានអោយចៃធ្វើអី?

ខ៖ ខ្ញុំនៅកាលនុងដូចថានៅកុមារណា!

ក៖ ចឹងនៅកុមារនោះទេហេស?

ខ៖ចាសនៅកុមារ!

ក៖ហើយពេលនុងគេបានអោយចៃធ្វើអី?

ខ៖ កាលនុងដាច់ហើយពេលនុងខ្ញុំបានមានអាយុបានបួនទៅដប់ឆ្នាំ។

ក៖ ចឹងចៃចង់ចាំនៅក្នុងរបប?

ខ៖ អូ! កាលនុងខ្ញុំបាននៅក្នុងរបបនុង១៨ឆ្នាំ

ក៖ ចុះកាលនុងគេបានអោយចៃធ្វើការងារអ្វី?

ខ៖ គេអោយធ្វើការងារធ្ងន់ៗណាស់! គេអោយទៅដកស្ទោស្រូវ
ហើយខ្ញុំទៅរែកដីនៅទំនប់តាកុត នៅទំនប់តាកុតនុងរែកឡើងរហូតនុងណា
កាលនុងដីរបបល្បប់ល្អណាស់ ដាក់ទៅស្រូវននុងដឹងថាល្អមែន។

ក៖ ចឹងកាលនុងគេបានប្រើចៃអោយដកស្រូវ!

ខ៖ អឹម

ក៖ ចឹងចែកាលនុងតើចែមានការជួបការលំបាកអ្វីខ្លះក្នុងការដេកស្មៅស្រូវនុង?

ខ៖ការងារនុងវាធ្ងន់ ហើយថាវាមិនបានធ្ងន់អីប៉ុន្មាននោះទេវាក្តៅណា! ដូចថាវាគ្មានម្ជូកអីពាក់នោះទេ! ពេលធ្វើចឹងទៅដូចថាមានខ្លះបានម៉ោង១០ទៅ១១អីបានអោយយើងឡើង។

ក៖ ប៉ុន្មានម៉ោង?

ខ៖ ប៉ុន្មានម៉ោង ដឹងថាឡើងមកហូបបបរទៀតគ្មានបានហូបបាយនោះទេ! បបរនុងឡើងរាវហើយលាយព្រលឹតទៀតនោះ។

ក៖ ចឹងអត់មានកំលាំងទេ

ខ៖ តើមានកំលាំងអីបើសិនជាញុំាតែបបរចុង! តើមានកំលាំងស្អី!

ក៖ ចាស

ខ៖ដូចថាមានតែស្បែកនិងឆ្អឹងគ្មានសាច់និងឈាមនោះទេ!

ក៖ ចឹងបានបន្ទាប់ពីនុងមកគេបានប្រើអោយទៅរែកដីនៅតាកុតទៀត?

ខ៖ រែកដីទៀត!

ក៖ តើរែកនៅនុងតើគេបានដាក់ផែនការណ៍ តើនៅក្នុង១នាក់បានប៉ុន្មាន?

ខ៖ រែកអត់មានបាននោះទេ ក៏ប៉ុន្តែប្រធានកងនុងគាត់ចេះតែយោគយល់ចឹងទៅ! ព្រោះអីប្រធាងកងនោះគាត់បានអាណិតយើងនោះ។

ក៖ ចាស!

ខ៖ ហើយប្រធានកងនុងមានអាក្រក់និងល្អ! កាលនុងប្រធានកងគឺពូផានៅទឹកចេញនេះបានគេបាញ់ងាប់ចឹង ហើយចៅតាអាននេះឡើងខ្មៅ មីនុងក៏អាក្រក់ដែរ ។ កាលនៅកងជាមួយនឹងគ្នាវាបានប្រើយើងអាក្រក់ណាស់ដែរ រួចបើសិនជាខ្ញុំនៅកងផានុង

គាត់បានថាចែក អូនឯងតូចជាងគេចឹងហើយមកនេះមក!!
ដល់ពេលកាប់អោយបងចឹងហើយខ្ញុំជាអ្នករែក ដល់ពេលហើយចឹងគេបានរែក១ដើងទៅ
វាបានទៅនិយាយអីឯណាឯនែចឹងទៅយើងមិនទៅរករឿងអី
ដល់ពេលយើងកូនក្រុមយើងប្រឹងរែក។

ក៖ អូចាស!

ខ៖ ចឹងបានថា តែអាណិតតែប្រុសៗនោះទេវៃគ្នាចោលនៅឯនុង។

ក៖អូ

ខ៖ ឪពុកមារបស់ខ្ញុំអីគេបានយកទៅវៃចោលនៅឯតាកុតនុង!

ក៖ ចឹងអ្នកដែលរែកហើយគេយកទៅវៃចោលភ្លាមៗនុងយ៉ាងម៉េច?តើបានខុសអ្វីគេ?

ខ៖ គ្មានធ្វើខុសអីនោះទេ!វាចង់និយាយថាយើងប្រវត្តិមិនល្អ បងប្អូនបានធ្វើចឹង
គឺមានជាប់ខ្សែសេអ៊ីអាអីវានុង ចេះតែថាចឹងទៅណា។

ក៖ ចឹងចូលបកស្រាយទៅមើលថាអីគេខ្សែសេអ៊ីអានុង?

ខ៖គេថាយើងហ្នឹង ជាប់ខ្សែអេអ៊ីអាអីវា!

ក៖ចឹងខ្សែអេអ៊ីអានុងគឺប្រវត្តិរបស់យើង!

ខ៖ ប្រវត្តិរបស់យើងធ្វើការជាប់សេអេអ៊ីអានុងដែលអាពតបានចំណាំនិយាយតែចឹងនោះ
ហើយបងរបស់ខ្ញុំ២នាក់នុងក៏ចឹងដែរបានធ្វើការប្រឹងណាស់ មិនហ៊ានប្រលះអីនោះទេណា
តែគេបានយកទៅវៃចោល ព្រោះវាបានចោទយើងថាយើងនេះលួចនេះលួចនោះអីចឹងទៅ!។

ក៖ អូ្វយ!

ខ៖ តែតាមពិតយើងគ្មានបានទៅលួចអីនោះទេ ស្លូតៗសឹងអីនុង។

ក៖ រួចទៅបន្ទាប់ពីនុងទៅចៃ គេបានអោយទៅធ្វើអីគេទៀត?

ខ៖ ខ្ញុំហើយដល់ពេលបានបន្ទាប់ពីនុងមក គេបានអោយខ្ញុំទៅធ្វើស្រែស្រូវ
ដកស្ទូងនិងចល័តទៅនេះទៅនោះចឹងទៅ ទៅទឹកចេញ ទៅ
ហើយទៅនោះចឹងទៅស្ទូងស្រូវច្រូតនុង នៅខែច្រូតក៏ច្រូតទៅ
ដល់ពេលខែនេះវាបានស្រូវ៣ទៅ៤តោនរបស់វា ហើយទៅលាយជីលាមកមនុស្សទៀត
បានលាយជីអាចម៍គោ លាមករបស់មនុស្សអីចឹងនុង
លាយអាហ្នឹងទៀតយកទៅចាក់នៅក្នុងស្រូវ
ហើយដល់ពេលយប់នុងវាបានអោយយើងទៅចាប់កណ្តុរទាំងយប់ទៀត
ចល័តអោយឯងទៅចំការឪឡឹកទៅ ទៅភូមិនេះភូមិនោះចឹងទៅបានទៅអណ្តូងដៃ
ទឹកចេញចឹងទៅ។

ក៖ នៅពេលថ្ងៃប្រើយើងដកស្ទូងចឹងហើយដល់ពេលយប់ឡើងប្រើយើងដេញកណ្តុរទៀត?

ខ៖ ដេញកណ្តុរទៀត!

ក៖ ចឹងគ្មានបានដេកនោះទេចឹង?

ខ៖គ្មានបានដេកអី យប់ទាល់តែម៉ោងប្រលប់ៗមិនអោយយើងចេញទៅនោះទេ ស្វាត់
អោយកណ្តុរវាស៊ីពោត ហើយចឹងម៉ែឯណាប្រើយើងអោយទៅដេកកណ្តុរកុំអោយវាស៊ីពោត!។

ក៖ហឹម!

ខ៖ ហាសៗបើសិនជាម្តាយរបស់ខ្ញុំវិញយំ
ដែលយកកូនគាត់ទៅសម្លាប់ចោលនៅមុខគាត់នោះ។

ក៖ ចឹងគេអោយគាត់ឃើញ!

ខ៖ ឃើញ យកទៅនុងមុខ ខ្ញុំក៏ឃើញដែរ! ខ្ញុំឈឺចាប់មែនទែន!
អត់មានហ៊ានបានមើលបងនោះទេណា!

ក៖ ចាស

ខ៖ គេបានចាប់ចង់ឡើងក្រងើតចឹង រត់មើលទេ។

កៈ ចឹងនៅពេលនុងថៃ នៅក្នុងរបបនុង នៅក្នុងគ្រួសារ គេបានបំបែកគ្នាអស់ហើយ?

ខៈ សុតតែបំបែក
កាលពេលនៅក្នុងគ្រួសារនុងគេបានចាប់បងចឹងទៅហើយជួនកាលអ្នកដែលបានធ្វើការនៅជិ
តយើងនុងគេមិនបានមកជិតយើងនោះទេ គេថាចេះចុះអីចឹងទៅណា។

កៈគេនិយាយ!

ខៈ ហ្នឹងហើយថាប្រវត្តិមិនល្អអីចឹងទៅ!
ហើយដល់ពេលយើងនេះក៏នៅស្ងាត់ស្ងាមអីចឹងទៅអត់ហ៊ានទៅថាអោយគេនោះទេ
ហើយជួនកាលគេបានម៉ាកងាយយើងអីចឹងថាយើងប្រជាជនថ្មីអីចឹងទៅណា។

កៈ
ថៃមុននឹងបញ្ចប់តើថៃមានមតិយោបល់អ្វីដើម្បីផ្តាំផ្ញើដល់កូនចៅនិងប្អូនៗជំនាន់ក្រោយណា?

ខៈ
ជាទីបញ្ចប់នុងខ្ញុំសូមផ្តែផ្តាំដល់កូននិងក្មេងៗជំនាន់ក្រោយទាំងអស់ហ្នឹងអោយខិតខំរៀនសូត្រ
ព្រោះអីខ្ញុំវាបានធ្លាប់ជួបការលំបាកដូចជាការរកស៊ី វាមិនជោគជ័យរហូតនោះទេ
មានតែរៀនមានតែចំណេះដឹងនុងហើយដែលយកទៅប្រើប្រាស់
មានគោលដៅនៅថ្ងៃអនាគត។

កៈ បានប្រាក់ខែជាអាជីពមក ហើយបានស៊ីមួយជីវិតណ៎?

ខៈ ចាស!

កៈ ចាសហើយចុះមានអ្វីទៀតដេស?

ខៈ ចាស

កៈ ចាសចឹងថៃមានមតិយោបល់ទៀតដូចជាសូមអោយថៃរក្សា?

ខ៖ រក្សាប្រពៃណីខ្មែរយើងនិងការស្លៀកពាក់ ហើយនិងការរៀបអាពាហ៍ពិពាហ៍ អោយមានកេរ្តិ៍ឈ្មោះដល់ម្តាយនិងឪពុក អោយមានកេរ្តិ៍យក កុំអោយថាទុំមុនស្រគៀល នំធំជាងនាអីចឹងណា។

ក៖ ចាសមានទៀតដេសថៃ?

ខ៖ អស់ហើយ

ក៖ ចឹងថៃខ្ញុំសូមអរគុណថៃច្រើនដែរបានលះបង់ពេលវេលា អោយខ្ញុំធ្វើការសម្ភាសដឹងអំពីជីវៈប្រវត្តិរបស់ថៃ ចាស!ចឹងខ្ញុំសូមថតរូបរបស់ថៃ១ប៉ុសនិងបទសម្ភាសហ្នឹងយកទៅដាក់នៅសកលវិទ្យាល័យBYUនៅសហរដ្ឋអាមេរិក ចឹងថៃតើអនុញ្ញាតដើម្បីអោយខ្ញុំយកទៅដាក់នៅគេហៈទំព័រនុងទេ?

ខ៖ ចាសខ្ញុំអនុញ្ញាត!

ក៖ចឹងខ្ញុំសូមជូនពរថៃអោយមានអាយុវណ្ណៈសុខៈពលៈកុំម្បីឃ្លានឃ្លាតឡើយចាសខ្ញុំសូមអរគុណច្រើន។